**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ១៩៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់ប្រើប្រាស់ដោយចីរភាព លើផ្ទៃដីទំហំ ៣០,៩១ ហិកតា (សាមសិបហិកតា និងកៅសិបមួយអា) ស្ថិតនៅក្នុងឧទ្យានជាតិកែប ភូមិសាស្រ្ត សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប និងការធ្វើអនុប្បយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់ជាតំបន់ប្រើប្រាស់ដោយចីរភាព ផ្ទៃដីទំហំ ៣០,៩១ ហិកតា (សាមសិបហិកតា និងកៅសិបមួយអា) ស្ថិតនៅក្នុងឧទ្យានជាតិកែប ភូមិសាស្ត្រសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ដូចមានផែនទី និងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន ឌីភីអិលខេ អ៊ិនវេសម៉ិន គ្រុប ឯ.ក (DPLK INVESTMENT GROUP CO.,LTD.) ដើម្បីបន្តរៀបចំបំពេញបែបបទនីតិវិធី ជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២.-**

ត្រូវបានធ្វើអនុប្បយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ផ្ទៃដីទំហំ ៣០,៩១ ហិកតា (សាមសិបហិកតា និងកៅសិបមួយអា) ដូចមានក្នុងមាត្រា១នៃអនុក្រឹត្យនេះ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋក្រោមលក្ខខណ្ឌជួលឱ្យក្រុមហ៊ុន ឌីភីអិលខេ អ៊ិនវេសម៉ិន គ្រុប ឯ.ក (DPLK INVESTMENT GROUP CO.,LTD.) សម្រាប់វិនិយោគលើគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ ដែលត្រូវស្ថិតក្រោមការចាត់ចែង នីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងក្រសួងស្ថាប័នពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកែប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ២ កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ផែនទី ទីតាំងគម្រោងស្នើសុំអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ របស់ក្រុមហ៊ុន ឌីធីអិលខេ អ៊ិនវេសមិន គ្រុប ៦.ក**
**ស្ថិតក្នុងឧទ្យានជាតិកែប ភូមិសាស្ត្រសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប**

ផែនទី និងចំណុចនិយាមកានេះ ជាឯកសារភ្ជាប់នឹងអនុក្រឹត្យលេខ១៩៨ អនក្រ.បក ថ្ងៃ.សុក្រ.....២..កើត... ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ចុះថ្ងៃទី..១៩.. ខែ.កក្កដា....ឆ្នាំ២០២៣




| Id | X | Y | Id | X | Y |
|---|---|---|---|---|---|
| 1 | 424174 | 1162263 | 14 | 423966 | 1161716 |
| 2 | 424291 | 1162117 | 15 | 423853 | 1161855 |
| 3 | 424408 | 1161971 | 16 | 423740 | 1161994 |
| 4 | 424332 | 1161932 | 17 | 423702 | 1162074 |
| 5 | 424302 | 1161894 | 18 | 423686 | 1162175 |
| 6 | 424295 | 1161853 | 19 | 423706 | 1162221 |
| 7 | 424247 | 1161797 | 20 | 423741 | 1162275 |
| 8 | 424238 | 1161761 | 21 | 423790 | 1162319 |
| 9 | 424223 | 1161742 | 22 | 423858 | 1162368 |
| 10 | 424227 | 1161722 | 23 | 423913 | 1162357 |
| 11 | 424204 | 1161697 | 24 | 423898 | 1162325 |
| 12 | 424113 | 1161663 | 25 | 424051 | 1162299 |
| 13 | 424044 | 1161666 | | | |

**ទំហំ ៣០,៥១ ហិកតា**

**ឧទ្យានជាតិកែប**




**សញ្ញាសម្គាល់**
- ចំណុចនិយាមកា
- ព្រំប្រទល់ឃុំ/សង្កាត់
- ខ្សែរយៈកម្ពស់
- ទីតាំងគម្រោង
- ព្រំប្រទល់ឧទ្យានជាតិកែប

Google Satellite